អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៣ ខែសីហា ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# ជប៉ុនផ្តល់វិភាគទានថ្មីជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

រដ្ឋាភិបាលជប៉ុនបានប្រកាសផ្តល់វិភាគទានថ្មីចំនួន ១ ២២១ ៨១៨ ដុល្លារអាមេរិក ដល់ភាគីអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) សម្រាប់ប្រើប្រាស់នៅឆ្នាំ ២០១៧។ វិភាគទានថ្មីនេះ បានធ្វើឱ្យជំនួយហិរញ្ញវត្ថុ ដែលផ្តល់ដោយរដ្ឋាភិបាលជប៉ុនមកកាន់ទាំងភាគីជាតិ និងអន្តរជាតិនៃ អ.វ.ត.ក កើនចំនួនដល់ប្រមាណ ៨៦ លានដុល្លារអាមេរិក ឬស្មើនឹងប្រមាណ ៣០.៦% នៃការផ្តល់វិភាគទានសរុបរបស់ក្រុមប្រទេសម្ចាស់ជំនួយ នៅត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៧ និងធ្វើឱ្យជប៉ុននៅតែជាប្រទេសផ្តល់ជំនួយធំជាងគេបំផុតរបស់ អ.វ.ត.ក ចាប់តាំងពីតុលាការនេះដំណើរការមក។

ឯកឧត្តម ក្រាញ់ តូនី ប្រធានការិយាល័យរដ្ឋបាលស្តីទី និងលោក ឃ្នុត រ៉ូហ្សិនហាក អនុប្រធានការិយាល័យរដ្ឋបាល មានប្រសាសន៍ថា៖ "ក្នុងនាម អ.វ.ត.ក យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ និងអរគុណយ៉ាងស្មោះស្ម័គ្រចំពោះរដ្ឋាភិបាលជប៉ុន ដែលបានគាំទ្រ និងបន្តផ្តល់វិភាគទានហិរញ្ញវត្ថុដ៏មានសារៈសំខាន់នេះ។ ជំនួយហិរញ្ញវត្ថុថ្មីនេះ ពិតជាមានភាពចាំបាច់សម្រាប់ អ.វ.ត.ក ដើម្បីបញ្ចប់អាណត្តិការងាររបស់ខ្លួន ដោយមិនមានការរអាក់រអួលក្នុងកិច្ចដំណើរការនីតិវិធីឡើយ"។

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*

**លោកស្រី ហាយ៉ាត់ អាបូសាឡេស**
មន្ត្រីព័ត៌មានសាធារណៈ
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ៩៣៦
សារអេឡិកត្រូនិកៈ abusaleh@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទចល័តៈ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh